# ព្រឹត្តប័ត្រព័ត៌មាន អេកូសន
# ECOSORN NEWSLETTER

លេខទី ៣, ខែ មេសា ឆ្នាំ ២០០៨ — Issue 3, April 2008




## អណ្តូងស្នប់រ៉ៃ

បច្ចុប្បន្ននេះ ក្នុងចំណោមប្រជាពលរដ្ឋនៃខេត្តសៀមរាប គឺមានប្រជាពលរដ្ឋចំនួន ៣០% ប៉ុណ្ណោះ ដែលមានលទ្ធភាពប្រើប្រាស់ទឹកប្រកបដោយសុវត្ថិភាព។ ប៉ុន្តែប្រជាពលរដ្ឋភាគច្រើនបានប្រើប្រាស់ទឹកនៅលើដី ឬប្រភពទឹកក្នុងដីមានជំរៅរាក់ដែលមានមេរោគជាច្រើន ហើយអណ្តូងភាគច្រើន តែងតែរីងហួតនារដូវប្រាំង នៅពេលដែលចរន្តទឹកក្រោមដីធ្លាក់ចុះ មូលហេតុដោយសារអណ្តូងទាំងនោះ ជីកនៅក្នុងកំឡុងរដូវវស្សា។

ម្យ៉ាងទៀតគ្រួសារភាគច្រើនរស់នៅតំបន់ជនបទ គ្មានប្រាក់ចំណូលគ្រប់គ្រាន់ថែមទាំងគ្មានទឹកស្អាតប្រើប្រាស់ និងគ្មានការយល់ដឹងអំពីផលវិបាក បង្កឡើងដោយសារតែការប្រើប្រាស់ទឹកកខ្វក់ ដែលជាហេតុនាំឱ្យមានជំងឺកើតឡើង ធ្វើអោយគ្រួសារចំណាយប្រាក់ជាច្រើនពីប្រាក់ចំណូលរបស់ខ្លួនជារៀងរាល់ឆ្នាំ លើការថែទាំព្យាបាលសុខភាពគ្រួសាររបស់ពួកគេ។ ដូច្នេះការចំណាយនេះ ធ្វើអោយជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេមានការលំបាក ហើយនៅទីបំផុត ធ្វើឱ្យពួកគេឈានទៅរក ការជំពាក់បំណុលយ៉ាងធ្ងន់ធ្ងរទៀតផង។

ដោយហេតុផលដូច្នេះហើយទើប គំរោងអេកូសន បានអនុវត្តកម្មវិធីសាងសង់អណ្តូងទឹកមានស្នប់រ៉ៃ មានទឹកប្រើប្រាស់គ្រប់គ្រាន់ពេញមួយឆ្នាំ និងមានសុវត្ថិភាពជាងអណ្តូងទឹក ដែលមានពីមុនមក ។ ចំណែកបទដ្ឋានបច្ចេកទេសនៃការសាងសង់អណ្តូងត្រូវបានអនុវត្តយ៉ាងហ្មត់ចត់ ក្នុងការកំណត់ពីជំរៅ ដែលត្រូវការដើម្បីធានាថាអណ្តូងមានទឹកប្រើប្រាស់គ្រប់គ្រាន់ ក្រោយពេលសាងសង់រួចរាល់។

*តទៅទំព័រទី២*

## Well with Rovai Pump

Nowadays 30 % of the rural population in Siem Reap use safe water, but most inhabitants have accessed to bacteriological contaminated ground surface or shallow water sources. More over, many hand dug wells dry up when the water tables drop in the dry season since they were constructed in the rainy season.

Most families living on insufficient income in rural areas either have not accessed to clean water or are unaware of the consequence in the use of contaminated water which can be borne in disease, and the recur in the recent year makes the households spend a large amount of their income every year for the family's health. For that reason, the expenses suffer their daily lives and eventually cause them into a serious debt.

For that reason, Ecosorn programme is to install the hand dug wells with Rovai pump for a year-round water supply will be safer water than the former infrastructures. Technical specifications are strictly complied to determine the depth requirements to ensure sufficient water in the well after its construction completed.

The five-month QIP (April-August 2007) implemented by Mr. Chom Savat, contractor, on the purpose of supplying safe water to Ecosorn beneficiaries in the selected target villages, who lack clean water in both seasons.

***Continued on page 2***

## Well with Rowei Pump...

***Continued from page 1***

Benefit from water supply and sanitation facilities:

- Encouraging household practices related to water and sanitation.
- Improving the target people's health in the community.
- Introducing appropriate technologies to be used after the project phases out.
- Utilizing the water for vegetable production.

The Quick Impact Project is really bringing a better quality of community's lives from saving time and energy from water collection, and using clean, safe and reliable water. This behaviour change has led the community to get better life. Drinking clean water for good health is the key factor to succeed in rural development activities.

## អណ្តូងរ៉ូវៃ...

គំរោងខ្នាតតូច (ពីខែមេសា ដល់ខែសីហា ឆ្នាំ២០០៧) មានគោលបំណងផ្តល់ទឹក ប្រកបដោយសុវត្ថិភាពដល់អ្នកទទួលផលរបស់គំរោងអេកូសននៅក្នុងភូមិគោលដៅដែលបានជ្រើសរើសដែលខ្វះខាតទឹកស្អាតប្រើប្រាស់ទាំងពីររដូវ ។

ផលប្រយោជន៏ដែលបានមកពីសេវាទឹកស្អាត និងអនាម័យមាន :

-លើកទឹកចិត្តអោយមានការអនុវត្តក្នុងគ្រួសារស្តីពីទឹកស្អាត និងអនាម័យ
-លើកកំពស់សុខភាពប្រជាពលរដ្ឋក្នុងសហគមន៏គោលដៅ
-ណែនាំឱ្យប្រើប្រាស់បច្ចេកវិទ្យាសមស្របក្រោយពេលគំរោងដកខ្លួនចេញ
-ទឹកក៏អាចយកមកប្រើប្រាស់សម្រាប់ផលិតផលដំណាំបន្លែផងដែរ ។

គំរោងខ្នាតតូចនេះ គឺជាគំរោងដែលជួយអោយជីវភាពរស់នៅរបស់សហគមន៏ប្រកបដោយគុណភាព តាមរយះការសន្សំសំចៃពេលវេលា និង កំលាំងពីការដងទឹក ឬ ស្វែងរកទឹកដែលប្រកបដោយសុវត្ថិភាព អនាម័យ និង គួរជាទីទុកចិត្តបានក្នុងការយកមកប្រើប្រាស់ ។

ការអនុវត្តនេះជាទំលាប់មួយដ៏ប្រពៃជួយអោយសហគមន៏រស់នៅប្រកបដោយភាពសុខដុមរមនា ។

ការហូបទឹកស្អាតគឺជាកត្តាគន្លឹះនាំអោយមានសុខភាពល្អនិងភាពជោគជ័យលើសកម្មភាពអភិវឌ្ឍមូលដ្ឋាន ។

## *Bee Keeping*

ECOSORN Project has provided training to the traditional honey-hunters and others in appropriate technology beekeeping, and introducing sustainable honey-harvesting techniques, honey/wax processing, quality control and marketing to 10 beneficiaries aged 18-50 and the disable who occupies small land at Banteay Chmar Cheung and Banteay Chmar Lec village, Banteay Chmar Commune, Thmor Puok district, Banteay Meanchey province.

Training topic was about:
-Construction of top bars and hives
-Locating bee swarms and colonies
-Capturing as many swarms as possible
-Transferring as many colonies as possible
-Identifying queen bee
-Introducing beneficiaries to appropriate beekeeping tools
-Gauging the interest and enthusiasm of participants

The project aims at contributing to poverty reduction in a rural and remote commune by developing an income-generating activity.

## របរចិញ្ចឹមឃ្មុំ

គំរោងអេកូសនបានផ្តល់ការបណ្តុះបណ្តាលសំរាប់អ្នកប្រមាញ់ឃ្មុំតាមបែបប្រពៃណី និងអ្នកផ្សេងទៀត អំពីបច្ចេកទេសសមស្របក្នុង ការចិញ្ចឹមឃ្មុំ និង ណែនាំពីបច្ចេកទេសប្រមូលផលទឹកឃ្មុំប្រកបដោយចីរភាព ការកែច្នៃទឹកឃ្មុំ ក្រមួនឃ្មុំ ការគ្រប់គ្រងគុណភាព និង ទីផ្សារជាដើមដល់អ្នកទទួលផល ចំនួន ១០នាក់ ដែលជា កសិករមានវ័យពី ១៨-៥០ឆ្នាំ និង ជនពិការដែលមានដីតិចតួច នៅភូមិបន្ទាយឆ្មារជើង និង បន្ទាយឆ្មារលិច ស្ថិតក្នុងឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។



គំរោងបានចាប់ផ្តើមដោយការផ្តល់វគ្គបណ្តុះបណ្តាលស្តីពី :

-ការរៀបចំធ្វើបង្គងឃ្មុំ និងសំបុកឃ្មុំ
-ដាក់ក្រុមសត្វឃ្មុំ និងហ្វូងឃ្មុំ
-ចាប់ឃ្មុំឱ្យបានច្រើនដែលអាចធ្វើទៅបាន
-ផ្ទេរហ្វូងឃ្មុំឱ្យបានច្រើនដែលអាចធ្វើទៅបាន
-កំណត់អត្តសញ្ញាណឃ្មុំញីបន្តពូជ
-ណែនាំអ្នកទទួលផលពីឧបករណ៍ចិញ្ចឹមឃ្មុំសមស្រប
-វាស់ស្ទង់ពីចំណាប់អារម្មណ៏ និងការគាំទ្ររបស់អ្នកចូលរួម ។

គំរោងនេះមានគោលបំណងរួមចំណែកកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទដាច់ស្រយាលតាមរយះការបណ្តុះបណ្តាលវិជ្ជាជីវៈពិតប្រាកដដល់អ្នកទទួលផល និងការបង្កើនប្រាក់ចំណូល ។

# អនាម័យជនបទ

បង្គន់អនាម័យជាលក្ខណៈគ្រួសារត្រូវបានផ្តល់ដោយគំរោងអេកូសនដល់ភូមិគោលដៅសម្រាប់ផ្តល់អនាម័យ ដែលជាកត្តាសំខាន់នៃសុខភាព។ អ្នកទទួលផលត្រូវបានបង្ហាញពីជំរើសបច្ចេកវិទ្យាផ្សេងៗគ្នា ដោយផ្អែកលើ “សៀវភៅណែនាំស្តីពីការជ្រើសរើសបង្គន់អនាម័យជាលក្ខណៈគ្រួសារជនបទ” ដែលចេញផ្សាយដោយក្រសួងអភិវឌ្ឍន៏ជនបទក្នុងខែមករាឆ្នាំ២០០៦ ហើយអ្នកទទួលផលភាគច្រើនមានចំណូលចិត្តទៅលើបង្គន់ចាក់ទឹកជាង។ ដូច្នេះ ការគ្រោងប្លង់សំរាប់បង្គន់អនាម័យចាក់ទឹកត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង ជាពិសេសនៅតំបន់ដែលមានទឹកជំនន់ ឬ តំបន់ដែលមានជំរៅទឹករាក់។

ការអនុវត្តន៏ត្រូវបានធ្វើឡើងតាមដំណើរការដូចតទៅនេះ : ទី១ គ្រួសារអ្នកទទួលផលត្រូវបានជ្រើសរើសដោយ គណកម្មាធិការអភិវឌ្ឍភូមិ ដើម្បីទទួលបង្គន់អនាម័យដោយផ្អែកលើសេចក្តីណែនាំរបស់គំរោងអេកូសន។ ទី២ អ្នកទទួលការក្នុងស្រុកដែលជាអ្នកទទួលសាងសង់បង្គន់ និងដោយមានការចូលរួមបដិភាគពីសំណាក់គ្រួសារអ្នកទទួលផលជាថវិកានិងជាកំលាំងពលកម្មដោយស្ម័គ្រចិត្ត។ ទី៣ គុណភាពការងារត្រូវបានត្រួតពិនិត្យ យ៉ាងហ្មត់ចត់ពីអ្នកគ្រប់គ្រងផ្នែកបច្ចេកទេសរបស់គំរោងអេកូសន និង ទីបញ្ចប់អ្នកបច្ចេកទេសក្នុងស្រុកត្រូវបានលើកទឹកចិត្តអោយចូលរួមដើម្បីអោយពួកគេមានសមត្ថភាពសាងសង់បង្គន់ដោយខ្លួនឯងផ្ទាល់នៅក្នុងភូមិដោយប្រើប្រាស់ថវិកាផ្ទាល់របស់ពួកគេ។



បទពិសោធន៏ជាគន្លឹះដែលទទួលបាន :
-មានការយល់ដឹងខ្ពស់ពីអត្ថប្រយោជន៏នៃសុខភាពតាមរយៈការការប្រើប្រាស់បង្គន់អនាម័យ
-មានការលំបាកចំពោះគ្រួសារក្រីក្របំផុតដែលគ្មានលទ្ធភាពចូលរួមក្នុងកម្មវិធីសាងសង់បង្គន់ ហើយឧបសគ្គ ដ៏សំខាន់នោះ គឺបណ្តាលមកពីការខ្វះខាតថវិកា ឬ កំលាំងពលកម្ម។
- យើងសង្កេតឃើញថា គ្រួសារភាគច្រើនចង់បានបង្គន់ភ្ជាប់ទៅនឹងបន្ទប់ទឹក
-គ្រួសារមានថវិកាអាចលៃលក បរិច្ចាកថវិកាបដិភាគទៅលើការសាងសង់រចនាសម្ពន្ធ័ផ្នែកខាងលើគេអាចជ្រើសរើសយកគំរូមួយណាតាមធនធានដែលមាន។



## *Rural Sanitation*

Family latrines for the hygienic practices were introduced by the Ecosorn project to the target villages and beneficiaries were shown many technology choices based on the “Manual Book on Rural Household Latrine Selection” issued by MRD as of January 2006 and most of them prefer the Pour Flush Latrine. Therefore the special attention is paid to design Pour Flush Latrines in areas with flooding and/or shallow water table depths.

The process of project implementation such as: firstly the beneficiary families are selected by the Village Development Committees to receive the latrines based on Ecosorn guidelines; secondly local contractors constructed the latrines with assistance from the benefiting families by contributing voluntarily with their cash and labours. Thirdly the quality of work is regularly checked by the technical supervisors of the Ecosorn project. And lastly local technicians are encouraged to participate in so as to enable them to build their own latrines in the villages with their own funds.

Key Lessons learned:
- It was very highly aware of the health benefits from latrine usage.
- It was difficult to have the poorest of the poor to get involved in the latrine building programme - especially a bottleneck is caused from a lack of cash or manual labour.
- It is observed that many families prefer to combine a latrine with a bathroom into one.
- Families can afford to contribute are willing to build the superstructure with their choice of a model in available resources.

## *Potentials and Changing Farmer's Abilities*

Cambodia is a small and predominantly rural country with about 80 percent of population relies on agricultural production. Cambodian farmers, especially those who have been cultivating vegetables, crops and season, rice fields, emphasizing chemical pesticide is essential for preventing and killing pests in farming production. But most farmers never think the chemical pesticide is bad for their health and environment.

It is observed that farmers have spent lots of money on chemical pesticide for ages.

Prek Taven village about 70km from Battambang where is implementing support of mine clearance project for development of 30 direct beneficiaries. In that village people depend mainly on rice, orange and pineapple cultivation for a major source of income generation. Mr. Mea Cheurn, 47, who has lived in Prek Chik more than ten years, with seven family members but only three are at school.

Mea Cheurn with land of 7,500 square meters for growing vegetables usually buys seeds from market and if any problem happens to damage his crops, he used the chemical pesticide to deal with it and then he spends more money than vegetable cost he earns.

After the vegetables are harvested, the yield is low, so it makes his revenue insufficient for home consumption. Everyday Mr. Mear Cheurn can only earn 8,000 Riel in average per day.

Mea Cheurn, one of 30 trainees in May 2007 received official training on the topic of "Sustainable Home Garden" from Ecosorn-Sre Khmer in both theories and practices, allowing the participants to share their best practices and lessons learnt from the field. As a result, the participants acquire their skills and knowledge on techniques of agricultural cultivation and found that the project has a quick impact on the beneficiary's livelihood since Mea Cheurn can produce botanical fertilizers such as solid and liquid compost,

*continued on page 5*

## សក្តានុពលនិងការផ្លាស់ប្តូរសមត្ថភាពរបស់កសិករ

កម្ពុជា ជាប្រទេសតូចមួយដែលប្រជាពលរដ្ឋភាគច្រើនរស់នៅតាមតំបន់ជនបទ។ ប្រជាពលរដ្ឋចំនួន ៨០% ពឹងផ្អែកលើផលិតកម្មកសិកម្ម។ កសិករដាំបន្លែ ដំណាំស្រូវនិងដំណាំផ្សេងៗទៀតទៅតាមរដូវកាលដោយសង្កត់ធ្ងន់ទៅលើការប្រើប្រាស់ថ្នាំកសិកម្ម ដែលចាំបាច់ក្នុងការការពារ និងសំលាប់សត្វល្អិតចង្រៃដែល បំផ្លិចបំផ្លាញផលិតផលកសិកម្មរបស់គាត់។ ប៉ុន្តែប្រជាកសិករភាគច្រើនមិនបានគិតដល់ពីផលប៉ះពាល់អាក្រក់ដល់ សុខភាព និងបរិស្ថានឡើយ។

គេសង្កេតឃើញថា កសិករបានចំណាយប្រាក់យ៉ាងច្រើនទៅលើថ្នាំកសិកម្មសំលាប់សត្វល្អិត អស់រយៈពេលជាច្រើនឆ្នាំមកហើយ។

ជាក់ស្តែងនៅភូមិព្រែកតាវែន ស្ថិតនៅប្រហែល ៧០គីឡូម៉ែត្រ ពីខេត្តបាត់ដំបងដែលបាននឹងកំពុងអនុវត្ត គំរោងគាំទ្រការបោសសំអាតគ្រាប់មីនដើម្បីអភិវឌ្ឍដល់អ្នកទទួលផលផ្ទាល់ចំនួន ៣០គ្រួសារ។ ប្រជាពលរដ្ឋនៅក្នុងភូមិ ពឹងផ្អែកទាំងស្រុងលើ ដំណាំស្រូវ ក្រូច និងម្នាស់ ដែលជាប្រភពនៃប្រាក់ចំណូលមួយដ៏សំខាន់។

លោក មា ជឿន អាយុ ៤៧ ឆ្នាំ រស់នៅទីនេះជាង១០ឆ្នាំហើយ។គាត់មានផ្ទៃដីចំនួន ៧៥០០ ម៉ែត្រការ៉េសំរាប់ដាំបន្លែ។ តាមធម្មតាគាត់ទិញពូជពីផ្សារ នៅពេលបញ្ហាកើតមានឡើងដែលបំផ្លិចបំផ្លាញដំណាំរបស់គាត់ៗតែងតែប្រើថ្នាំកសិកម្មសំលាប់សត្វល្អិតដើម្បីដោះស្រាយបញ្ហាដោយបានចំណាយប្រាក់ច្រើនជាងប្រាក់ដែលគាត់ទទួលបានពីការលក់បន្លែ។

ក្រោយពេលគាត់ប្រមូលផលដំណាំបន្លែគាត់ទទួលបានផលទាប ដែលធ្វើឱ្យប្រាក់ចំណូលរបស់គាត់មិនគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់ជីវភាព។ ជារៀងរាល់ថ្ងៃគាត់រកប្រាក់ចំណូលបានជាមធ្យម ៨០០០រៀល ក្នុងមួយថ្ងៃ។



លោក មា ជឿន គឺជាសិក្ខាកាមម្នាក់ក្នុងចំណោមសិក្ខាកាម ៣០នាក់ ដែលកាលពីខែ ឧសភា ឆ្នាំ ២០០៧ គាត់បានទទួលវគ្គបណ្តុះបណ្តាលលើប្រធានបទ "សួនបន្លែគ្រួសារប្រកបដោយចីរភាព" ទាំងទ្រឹស្តី និងអនុវត្ត ដែលរៀបចំដោយគំរោងអេកូសន និងស្រែខ្មែរ។ វគ្គបណ្តុះបណ្តាលនេះបានផ្តល់ឱកាសអោយអ្នកចូលរួមចែករំលែកការអនុវត្តន៍ និងរៀនសូត្របទពិសោធន៍ពីចំការរបស់គេបានយ៉ាងប្រសើរ។

ជាលទ្ធផល អ្នកចូលរួមទទួលបានជំនាញនិងចំណេះដឹងពីបច្ចេកទេសកសិកម្ម។ គេសង្កេតឃើញថា គំរោងមានឥទ្ធិពលយ៉ាងឆាប់រហ័សដល់ការចិញ្ចឹមជីវិតរបស់អ្នកទទួលផល។ លោក មា ជឿន អាចផលិតជីធម្មជាតិ ដូចជាជីកំប៉ុស្តិ៍គោក និងជីកំប៉ុស្តិ៍ទឹក ថ្នាំសំលាប់សត្វល្អិតធ្វើពីរុក្ខជាតិ និង ...

តទៅទំព័រទី៥

តពីទំព័រទី៤

ការទុកដាក់គ្រាប់ពូជដែលទាំងនេះ គឺជាការចំណាយដ៏ចំបងលើថ្លៃ ផលិតកម្ម ដំណាំ-បន្លែ។

នៅពេល លោក មា ជឿន ជួបប្រទះបញ្ហាទាក់ទងនឹងការបំផ្លិចបំផ្លាញដោយសារសត្វល្អិតចង្រៃ គាត់លែងត្រូវការប្រើ ប្រាស់ ថ្នាំកសិកម្មទៀតហើយ។ ថែមទាំងអាចប្រើវិធីសាស្រ្តមេកានិច និងថ្នាំសំលាប់សត្វចង្រៃ តាមបែបធម្មជាតិ ក្នុងការបំបាត់សត្វល្អិតចង្រៃដើម្បីឱ្យផលិតកម្មដំណាំបន្លែរបស់គាត់កាន់តែប្រសើរ និង បង្កើនទិន្នផលទៀតផង។

លោក មា ជឿន មាន ចំណាប់អារម្មណ៏លើបច្ចេកទេសទាំងអស់នេះ ដោយប្រើប្រាស់សំរាប់ផលិតកម្មកសិកម្មក្នុងតំបន់របស់គាត់ដើម្បីបង្កើនប្រាក់ចំណូលជាមធ្យមពី ៨000រៀល ទៅ១៥000រៀល ក្នុងមួយថ្ងៃ។



គេសន្និដ្ឋានថា ដំណាំបន្លែគឺជាផ្នែកមួយដ៏ចាំបាច់ និង ដើរតួយ៉ាងសំខាន់ក្នុងផលិតកម្មកសិកម្ម ។ អ្នកទទួលផលរបស់គំរោងមិនមែនមានតែ លោក មា ជឿន តែម្នាក់ទេដែលមានលទ្ធភាពអនុវត្តបច្ចេក-ទេសសំរាប់ផលិតកម្មដំណាំបន្លែ ប៉ុន្តែថែមទាំងមានអ្នកទទួលផលផ្សេងទៀតបានអនុវត្តបច្ចេកទេសនេះ ក្នុងតំបន់ខុសៗគ្នាសំរាប់គ្រួសាររៀងៗខ្លួន។ ក្រៅពីនេះ វាបានជួយជំរុញការប្រើប្រាស់កសិជីវៈចំរុះ និង ធនធានក្នុងស្រុកដើម្បីធ្វើឱ្យផលិតភាពកសិកម្មរបស់គេកាន់តែប្រសើរឡើងក្នុងការរួមចំណែកដល់សន្តិសុខស្បៀងនិងជីវភាពកសិករឱ្យកាន់តែប្រសើរឡើងថែមទៀត។

CONTINUED FROM PAGE 4

botanical pesticide and seed keeping – those are main expenses on vegetable production cost.

When Mea Cheurn faces any problems regarding damages by the pest, he doesn't need to use chemical any more but can now apply mechanic method and botanical pesticide to eliminate the pest for better vegetable production increasing their yield. Mea Cheurn is very interested in all techniques using for agricultural production in his area to get increased in average income from 8000 to 15000Riel per day.

It is concluded vegetables are the mainstay to play important roles in agricultural production. The project beneficiaries not only Mr. Mea Cheurn has ability to applied techniques for vegetable production but also other beneficiaries applied in different plot site for individual family. Moreover, it enhances the use of agro biodiversity and local inputs for improving their agricultural productivity that contributes to food security and better life for farmers.

## *Fostering the creation of new models and increasing revenues*

The project aims at contributing to poverty reduction in a rural and remote commune, Paoy Char, in Phnom Srok district through providing quality of vocational training in weaving 100% Khmer golden silk hold in 5 patterns and techniques to replicate the work on traditionally weaved silk blankets to 10 weavers; and at the same time they ensure to access to market. So now, after they finish training at National Silk Centre, and they can also install the specialized weavers in their village with ensuring them to access to market.

## គាំទ្រការបង្កើតគំរូថ្មី និង បង្កើនប្រាក់ចំណូល





គំរោងមានគោលបំណងរួមចំណែកកាត់បន្ថយភាពក្រីក្រក្នុងតំបន់ជនបទដាច់ស្រយាលដែលស្ថិតក្នុងឃុំប៉ោយចារ ស្រុកភ្នំស្រុក តាមរយៈ ការផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈប្រកបដោយគុណភាព លើផ្នែកតម្បាញសូត្រមាសខ្មែរ១00% ចំនួន ៥ប្រភេទ និងបច្ចេកទេសយកលំនាំ តាមត្បាញភួយសូត្រតាមបែបប្រពៃណី ដល់អ្នក តម្បាញ ចំនួន ១0នាក់។ ទន្ទឹមនឹងនោះ ក៏ដើម្បីធានាក្នុងការលក់ផលិផលលើទីផ្សារផងដែរ។ ដូច្នេះក្រោយពីពួកគេបញ្ចប់វគ្គបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលកោសេយ្យវប្បកម្មជាតិពួកគេអាចក្លាយទៅជាអ្នកតម្បាញឯកទេសនៅតាមភូមិរបស់ពួកគេ និងធានាបាននូវការលក់ផលិតផលនៅតាមទីផ្សារ។

## Activities and Achievements, Banteay Meanchey

-Identification of IRDM target villages for project activity implementing at 29 villages (11 batch 1 villages & 18 batch 2 villages), 13 communes, in four target districts: Svay Chek, Thmor Puok, Preah Netr Preah, and Phnom Srok.

-QIP#001-Income Generation for rural women was implemented in Treas village and commune, Svay Chek district as of 25th April 2006 to 24th April 2007, in cooperation with ECOSORN-PDA with 29 female beneficiaries.

-220 households (20 households per village) in cooperation with ECOSORN-CEDAC were selected to be pilot farmers for the agriculture activities in 11 IRDM target villages of batch1.

-QIP#3-c - identification, TNA and initial training of village animal health workers/village animal officers in the IRDM villages/communes-Banteay Meanchey in cooperation with the office of animal production and health/ ECOSORN -PDA.

-QIP#15- Establishment of a Small Scale Commercial Fish Hatchery/Nursery was implemented in Thmor Puok and a nursery in Svay Chek district in cooperation with the Provincial Office of Fisheries.

-QIP#6 of Small Farmers Exchange Demonstration was implemented for agriculture activities in cooperation with CEDAC.

-QIP#4-A of Animal Health Diagnosis was implemented in the 11 target IRDM villages/communes in the 4 target districts.

Although they are only quick impact projects, they are very important in contribution to improve production for beneficiaries and other farmers on their farms and livelihoods. Through QIPs activities we learned more valuable experiences to be merits for our implementation of the big projects in the upcoming years, 2008-2010. They reflect especially the contribution to the development of people's lives in the rural areas of Banteay Meanchey province – one of the target areas for agricultural production.

## សកម្មភាព និងសមិទ្ធផល ខេត្តបន្ទាយមានជ័យ

-ការកំណត់អត្តសញ្ញាណភូមិគោលដៅកម្មវិធីអភិវឌ្ឍជនបទចំរុះសំរាប់សកម្មភាពគំរោងត្រូវបានធ្វើឡើងលើភូមិចំនួន ២៩ភូមិ (ជំហាន១ ចំនួនភូមិ១១ និងជំហាន២ ចំនួន ១៨ភូមិ) ១៣ឃុំ ក្នុងស្រុកគោលដៅទាំង ៤ មាន ស្រុកស្វាយចេក ថ្មពួក ព្រះនេត្រព្រះ និងស្រុកភ្នំស្រុក

-បានអនុវត្តគំរោងខ្នាតតូចលេខ ០០១ ស្តីពីការបង្កើតប្រាក់ចំណូលសំរាប់ស្ត្រីជនបទនៅភូមិ និងឃុំទ្រាស ស្រុក ស្វាយចេក ចាប់ពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦ រហូតដល់ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៧ សហការជាមួយគំរោង



អេកូសន-មន្ទីរកសិកម្មខេត្ត ក្នុងនោះមានស្ត្រីចំនួន ២៩នាក់ជាអ្នកទទួលផល

-កសិករចំនួន ២២០គ្រួសារ (២០គ្រួសារក្នុង-មួយភូមិ) សហប្រតិបត្តិការ (ឬ សហការ) ជាមួយគំរោង អេកូសន-សេដាកត្រូវបានជ្រើសរើសធ្វើជាកសិករគំរូ សំរាប់សកម្មភាពកសិកម្មនៅភូមិគោលដៅនៃកម្មវិធីអភិវឌ្ឍន៍ជនបទចំរុះ ក្នុងជំហានទី១។

-បានអនុវត្តគំរោងខ្នាតតូចលេខ ៣ ស្តីពីការកំណត់អត្តសញ្ញាណ ការវាយតម្លៃពីតំរូវការនៃការបណ្តុះបណ្តាល និងការបណ្តុះបណ្តាលជំហានដំបូងដល់ភ្នាក់ងារសុខភាពសត្វភូមិ មន្ត្រីពេទ្យសត្វភូមិ នៅតាមបណ្តាភូមិ-ឃុំ កម្ម-វិធីអភិវឌ្ឍជនបទចំរុះខេត្តបន្ទាយមានជ័យ ដោយសហប្រតិបត្តិការ (ឬ សហការ) ជាមួយការិយាល័យ ផលិតកម្ម និងបសុព្យាបាល ខេត្តរបស់គំរោងអេកូសន-មន្ទីរកសិកម្មខេត្ត

-បានអនុវត្តគំរោងខ្នាតតូចលេខ ១៥ ស្តីពីការ-បង្កើតកន្លែងថែបំប៉ននិងភ្ញាស់កូនត្រីជាលក្ខណៈពាណិជ្ជកម្ម ខ្នាតតូចនៅស្រុកថ្មពួក និង កន្លែងភ្ញាស់កូនត្រីនៅស្រុកស្វាយចេកដោយសហប្រតិបត្តិការ ជាមួយការិយាល័យជលផលខេត្ត

-បានអនុវត្តគំរោងខ្នាតតូចលេខ ៦ ស្តីពីការធ្វើបង្ហាញ និង ផ្លាស់ប្តូរបទពិសោធន៍ដល់កសិករសំរាប់សកម្មភាពកសិកម្មដោយសហប្រតិបត្តិ-ការជាមួយសេដាក

-បានអនុវត្តគំរោងខ្នាតតូចលេខ ៤ ស្តីពីការធ្វើរោគវិនិច្ឆ័យលើសុខភាពសត្វ ក្នុងភូមិ-ឃុំ គោលដៅនៃកម្មវិធីអភិវឌ្ឍជនបទចំរុះចំនួន១១ភូមិ-ឃុំ នៅក្នុងស្រុកគោលដៅទាំង ៤



ទោះបីជាគំរោងទាំងនេះជាគំរោងខ្នាតតូចក៏ដោយ ក៏វាមានសារៈសំខាន់បំផុតក្នុងការរួមចំណែកលើកកំពស់ផលិតកម្មរបស់អ្នកទទួលផល និងកសិករផ្សេងទៀតនៅលើកសិដ្ឋាន និង ជីវភាពរស់នៅ។

តាមរយៈសកម្មភាពគំរោងខ្នាតតូចទាំងនេះ យើងបានដកស្រង់នូវបទពិសោធន៍ដ៏មានតម្លៃជាច្រើនសំរាប់យកមកអនុវត្តគំរោងខ្នាតធំនៅឆ្នាំខាងមុខ (២០០៨-២០១០)។ ជាពិសេសវាបានឆ្លុះបញ្ចាំងពីការរួមចំណែកចំពោះការអភិវឌ្ឍន៍ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋនៅតំបន់ជនបទសំរាប់ផលិតកម្មកសិកម្ម។

# ប្រសិទ្ធភាពនៃច្បាប់ភូមិបាល

គំរោងអេកូសន-ខាដហ៏ សហការជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សំណង់ខេត្តបន្ទាយមានជ័យបានធ្វើការផ្សព្វផ្សាយច្បាប់ភូមិបាលក្រោមការឧបត្ថម្ភពីគម្រោងអេកូសនដល់ស្រុក ចំនួន០៤ ដូចជា : ស្រុកព្រះនេត្រព្រះ (ឃុំទានកាំ និង ឈ្នួរមានជ័យ) ស្រុកថ្មពួក (ឃុំគំរូ បន្ទាយឆ្មារ និងគោករមៀត) ស្រុកស្វាយចេក (ឃុំស្លរក្រាមនិងស្វាយចេក) ស្រុកភ្នំស្រុក (ឃុំពន្លៃ និងប៉ោយចារ)។

តាមរយៈការសង្កេត តាមដាន និង វាយតំលៃ ក្រុមការងារអង្គការខាដហ៏ យល់ឃើញថា មានសិក្ខាកាម ០១រូប ដែលតែងតែចូលរួមយ៉ាងសកម្មក្នុងការដោះស្រាយទំនាស់ដីធ្លីប្រកបដោយជោគជ័យ។

ក្នុងនាមជាអាជ្ញាធរ ភូមិ និង ឃុំ លោក ឃួន រ៉េត បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលជាច្រើនដែលទាក់ទង ទៅនឹងតួនាទី និងភារៈកិច្ចរបស់លោក។ ក្រៅពីវគ្គបណ្តុះបណ្តាលស្តីពីច្បាប់ភូមិបាលដែលលោកបានចូលរួមសិក្សា លោក បានចូលរួមវគ្គបណ្តុះ-បណ្តាលក្រោមការសំរបសំរួលពីអង្គការពុទ្ធ-



សាសនាដើម្បីអភិវឌ្ឍន៍ នៅឆ្នាំ២០០៣ និង គំរោងអេកូសននៅឆ្នាំ ២០០៧ផងដែរ។

លោកបានដោះស្រាយករណីជាច្រើនទាក់ទងនឹងទំនាស់ដីធ្លីដូចជា ទំនាស់ព្រំដីស្រែ ព្រំដីផ្ទះ ដីសម្បទានសង្គមកិច្ច ដីកេរ្តិ៍ ដីបញ្ចាំ ទំនាស់ដីជួល ដីផ្លូវ ឬទំនាស់រឿងបិទផ្លូវ ដីលំនៅដ្ឋាន ការរំលោភយកដីចំណីផ្លូវ និងការកាន់កាប់ដីភោគៈជាដើម។

ការសម្រុះសម្រួលរបស់លោកភាគច្រើន (៩០ភាគរយ) ត្រូវបានបញ្ចប់នៅថ្នាក់ភូមិ ដោយមិនបាច់បញ្ជូនទៅធ្វើការសម្រុះសម្រួលនៅថ្នាក់ឃុំឡើយគឺមានតែពីរករណីប៉ុណ្ណោះ ដែលបញ្ជូនទៅដល់ថ្នាក់ស្រុក (ដីជួល និង ដីបញ្ចាំ)។

បើទោះជាការបើកវគ្គបណ្តុះបណ្តាលស្តីពីច្បាប់ភូមិបាលនេះមានរយៈពេលតែ២ថ្ងៃក៏ដោយក៏ប៉ុន្តែសិក្ខាកាម ភាគច្រើនបានយក



**Land Law Training**

ចំណេះដឹងទាំងនេះ ទៅអនុវត្តនិងធ្វើការផ្សព្វផ្សាយដល់សហគមន៍មូលដ្ឋានក្នុងគោលបំណងលើកកំពស់ការយល់ដឹងពីច្បាប់ភូមិបាល។ តាមរយៈគំរោងនេះគឺពិតជារួមចំណែកកាត់បន្ថយទំនាស់ដីធ្លី និង ការគ្រប់គ្រងដីធ្លី ដើម្បីកាត់បន្ថយភាពក្រីក្រតាមរយៈកម្មវិធីអភិវឌ្ឍន៍ជនបទចំរុះ និងជា បទពិសោធន៍មួយសំរាប់ការអនុវត្តន៏គំរោងផ្សេងៗទៀត។

## *Effectiveness of Land Law*

ECOSORN-CARDH associated with DLMUPCC disseminates Land Law to Preah Netr Preah (Tean Kam& Chhnour Meanchey communes), Thmar Pouk (Kumrou, Banteay Chhmar& Kouk Romiet communes), Svay Chek (Slar Kram and Svay Chek communes), and Phnom Srok (Ponley and Poy Char communes).

Through observation, follow up and assessment, CARDH's Working Group found a trainee who has always participated well in problem-solving successfully.

In the position of an authority of village/commune, Mr. Khoun Reth has attended many training courses related to his tasks and duties. Besides from that land law training, he joined in training conducted by the Budhism for Development Organization in 2003 and ECOSORN project in 2007 as well.

He prove himself to be able to solve several cases regarding land conflicts such as: on Paddy field boundaries, housing land landmark, social land concession, land succession by heritage, land pawn, rented land, road land and road block, housing land (property), encroaching side road land, and over the land possession.

His coordination and facilitation are normally provided to the parties as a result of about 90 % cases were solved at village levels, having no needs to bring the cases to the commune level. So far there are only two cases brought to the district level (conflicts on land rent and pawned land).

Although the workshop was conducted only two days on the land law, most of trainees took their knowledge to implement the dissemination to the local community at the aim of enhancing the awareness on the land law.

Through the project will surely contribute to land conflicts alleviation and land management in order to reduce the poverty through rural development (IRDM) approaches and provide as the lessons learned for other project implementation.

## Fish Sauce Production

Chrey Commune, Moung Ruessei district is bounded by Tonle Sap Lake, where there is a potential area as a thousand tones of fishes are produced every year. The community didn't focus any attention on fish processing activities for more income generation from unused fleshly body of fish. This opportunity would be appreciated to the women group who are interested and willing to start their skill with the fish sauce production and practices. This Quick Impact Project was contracted to the Community Support Improve Development (CSID) at the above location in Battambang province. The project time frame is 12 months from 15 June 2007-15 June 2008.

Project purpose is to develop economic and employment opportunities, increase household income and minimizes migration from rural to urban and neighbouring countries. The project aims to create living environment of women with ability skill to improve the capacity of community empowerment and livelihood.

Women group is selected to provide training with Operation Production Center and practices is located in Chong Samnay village, Chrey commune in one of the poor villages with high potentials to fish processing.

## អាជីវកម្មផលិតទឹកត្រីខ្នាតតូច

ឃុំជ្រៃ ស្រុកមោងឬស្សី មានព្រំប្រទល់ជាប់បឹងទន្លេសាប ដែលជាតំបន់មានសក្តានុពលផ្តល់ទិន្នផលត្រីចំនួន ១000តោន ក្នុងមួយឆ្នាំៗ ។ សហគមន៍ពុំបានយកចិត្តទុកដាក់លើសកម្មភាពកែច្នៃត្រី ដើម្បីបង្កើនប្រាក់ចំណូលបន្ថែម ពីសាច់ត្រីទុកចោល ដែលមិនបានយកមកប្រើប្រាស់។ ឱកាសដ៏ល្អនេះ នឹងជួយលើកទឹកចិត្ត ដល់ក្រុមស្ត្រីដែលមាន ចំណាប់អារម្មណ៍ និងស្ម័គ្រចិត្តចាប់ផ្តើមជំនាញ និងអនុវត្តសកម្មភាពផលិតទឹកត្រីនេះ ។ គំរោងខ្នាតតូចនេះ ទទួលម៉ៅការអនុវត្តដោអង្គការអភិវឌ្ឍន៍ទ្រទ្រង់សហគមន៍ដែលមានទីតាំងស្ថិតក្នុង ខេត្តបាត់ដំបង។

គំរោងមានរយៈពេល ១២ខែ ដោយគិតចាប់ពី ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២00៧ ដល់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២00៨។

គោលបំណងគំរោងគឺ ដើម្បីបង្កើតកាលានុវត្តភាពសេដ្ឋកិច្ច និងឱកាសការងារបង្កើនប្រាក់ចំណូលគ្រួសារ និង កាត់បន្ថយចំណាកស្រុកពីតំបន់ជនបទទៅកាន់ទីក្រុង និងប្រទេសជិតខាង។

គំរោងមានគោលបំណង បង្កើតបរិយាកាសរស់នៅរបស់ស្ត្រី ប្រកបដោយសមត្ថភាពជំនាញ ដើម្បី ពង្រឹងសមត្ថភាពសហគមន៍ និងជីវភាពរស់នៅ។

ក្រុមស្ត្រីត្រូវបានជ្រើសរើស ដើម្បីឱ្យពួកគេទទួលបាននូវវគ្គបណ្តុះបណ្តាល និងបង្កើតមជ្ឈមណ្ឌលប្រតិបត្តិការ ផលិតកម្ម និងអនុវត្តដែលមានទីតាំងស្ថិតនៅភូមិចុងសំណាយ ឃុំជ្រៃ ដែលជាភូមិក្រីក្រមួយ និងមានសក្តានុពលខ្ពស់ក្នុងការកែច្នៃត្រី។



**ការិយាល័យគំរោងខេត្តសៀមរាប - Project Office, Siem Reap**
មន្ទីរកសិកម្ម ភូមិវត្តតំណាក់ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប
Provincial Department of Agriculture, Wat Damnak Village,
Salakamroek Commune, Siem Reap district, Siem Reap Province
P.O Box: 93241 Siem Reap Angkor
Tel: 063 965 478 - Fax: 063 761 243
Email: siem.reap.office@ecosorn.org

**ការិយាល័យគំរោងខេត្តបន្ទាយមានជ័យ - Project Office, Banteay Meanchey**
មន្ទីរកសិកម្ម ភូមិ២ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ
Provincial Department of Agriculture, Village II, Kampong Svay Commune,
Sereysophorn District, Banteay Meanchey Province
Tel/Fax: 054 710 344 - P.O Box: 105 Banteay Meanchey
Email: banteay.meanchey.office@ecosorn.org

**ការិយាល័យគំរោងខេត្តបាត់ដំបង - Project Office, Battambang**
មន្ទីរកសិកម្ម ផ្លូវជាតិលេខ៥ ភូមិរំចេក៤ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង
Provincial Department of Agriculture, National road #5, Romchek 4 village,
Rattanak commune, Battambang district, Battambang province.
Tel/Fax: 053 730 398 - P.O Box: 404 Battambang
Email: battambang.office@ecosorn.org

**ការិយាល័យសម្របសម្រួលភ្នំពេញ - Coordination Office, Phnom Penh**
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
Ministry of Agriculture, Forestry and Fisheries
#200, Norodom Blvd, Tonle Basak, Chamkarmon, Phnom Penh, Cambodia
Suite: #19-21, AIDOC building 1st floor - Tel/Fax: 023 223 786
Email: phnom.penh.office@ecosorn.org
**website: www.ecosorn.org**

MAFF MRD MORAM MOI MWA MLMUPC